ព្រះយេស៊ូវបានធ្វើការស្តីបន្ទោសទៅចំពោះពួកអាចារ្យ និង ពួកផារ៉ាស៊ី។ ដែលពួកគេបានទទួលនូវភាពស្រណុកសុខស្រួល ប៉ុន្តែ គេធ្វើដូចជាស្អប់នៃភាពស្រណុកសុខស្រួល។ ដូច្នេះពួកគេគឺជាមនុស្សដែលមានេជីវិតស្មោគគ្រោគនិងជាមនុស្សកំពុត។នៅពេលដែលមានមនុស្សប្រព្រឹត្តមិនស្អាតនៅក្នុងរោងឧបោសថ ពួកអាចារ្យទាំងនោះបានធ្វើការស្តីបន្ទោសទៅពួកគេ រួចបណ្តេញពួកគេចេញ ហើយបានប្រកាស់អំពីសេចក្តីសុចរិត។ដូច្នេះយើងគួតែសង់ននូវភាពជាព្រះជាម្ចាស់ឡើងវិញ ហើយយើងក៏ត្រូវការការស្រណុកតិចតួចដែរ *ប៉ុន្តែមិនមែនតាមបំណងខ្ញុំទេគឺតាមបំណងព្រះហរទ័យនៃព្រះវិញ* ។ មិនតែប៉ុនោះសោត យើងក៏គួតែស្រេចឃ្លាននូវសេចក្តីសុចរិតផងដែរ។ នេះហើយជាសិស្ស នៃព្រះជាម្ចាស់។

**ខ** យើងគួតែមានដូចនៅសេចក្តីមេត្តាករុណារបស់ព្រះគ្រិស្ទ។ យើងគួតែមាននូវសេចក្តីសុចរិតទាំងអស់គ្នា ការអត់ទោសឲ្យដោយគ្មានដែនកំណត់ និង សេចក្តីមេត្តាករុណា នេះហើយជាអត្តចរិតលក្ខណៈរបស់យើង។ តាមក្បួនខ្នាតនៃសេចក្តីមេត្តាករុណានៃព្រះគ្រីស្ទ គឺដូចជាខ្ពស់ណាស់សម្រាប់ឲ្យយើង

ស្រឡាញ់ខ្មាំងសត្រូវរបស់យើង។ យើងត្រូវតែផ្ដល់ក្ដីមេត្តាទៅពួកគេ ព្រោះការមេត្តាអាចយកឈ្នះការជំនុំជំរះរបស់ព្រះបាន។ សិស្សរបស់ព្រះយេស៊ូវគឺពេញដោយសេចក្ដីមេត្តាករុណា។

**គ** គ្រីស្ទបរិស័ទត្រូវតែមាននៅភាពស្មោះត្រង់។ជាឧទាហរណ៍គ្រីស្ទបរិស័ទត្រូវតែមាននៅភាពស្មោះត្រង់មួយរយភាគរយនៅក្នុងគំនិត ពាក្យសំដី និងសកម្មភាព។ ហើយការរស់នូវក្នុងការបន្ទាបខ្លួន។ ចំនែកការមានអំនួតអួតអាងនឹងធ្វើឲ្យយើងបរាជ័យបានយ៉ាងស្រួល។អស់អ្នកណាដែលមានចរិតលក្ខណៈទាំងបីនេះគឺជាសិស្សរបស់ព្រះជាម្ចាស់ហើយ។ហើយព្រះជាម្ចាស់ទ្រង់នឹងធ្វើការជាមួយគេរហូតទាល់តែគោលបំណងរបស់ទ្រង់ត្រូវបានបំពេញដោយមានវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ។ ជាឧទាហរណ៍ដូចជាលោកសាវ័កប៉ុលបានប្រគល់ជីវិតរបស់គាត់ទាំងស្រុងតាមការដោះស្រាយនៅបញ្ហារបស់គាត់ផ្ទាល់។នៅក្នុងឆ្នាំថ្មីនេះយើងគួតែមានការរីកចម្រើនលូតលាស់ឲ្យដូចជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទហើយដាក់ចិត្តដាក់កាយរបស់យើងដើម្បីផ្លាស់ប្ដូរអត្តចរិតរបស់យើង។

**ទីពីរៈ តើយើងធ្វើជាសិស្សរបស់ព្រះដោយរបៀបណា?**

សេចក្ដីបង្គាប់នៃការធ្វើជាសិស្សៈ *គឺជាការគ្រាប់តាមព្រះជាម្ចាស់ហើយសម្ដែងចេញមកពីព្រះជាម្ចាស់។* នៅក្នុងក្រុមជំនុំដំបូងរបស់កូរ មានការជាប់ទាក់ទងច្រើននៃការចង់ធ្វើជាសិស្សរបស់ព្រះ ប៉ុន្តែពួកគេមានការជាប់ទាក់ទងច្រើនទៅចំពោះព្រះគុណពិសេសតាមរយៈការជួបជុំអធិស្ឋាននៅលើភ្នំ និង ការជួបជុំនៃចលនានៃការផ្លាស់ប្រែ។ល។បន្ទាប់មកពួកគេធ្វើការទាក់ទងខ្លាំងនៅក្នុងការបង្វឹកបង្ហាត់នៃភាពជសិស្ស។ នៅក្នុងពាក្យមួយទៀតគឺថាៈ យើងគួតែបង្កើតអ្នកជិតខាងរបស់យើង ធ្វើឲ្យដូចជាសង្ឃហ្លួង។ នៅក្នុងលំដាប់លំដោយដើម្បីធ្វើជាសិស្សម្នាក់គឺត្រូវធ្វើឲ្យប្រាកដនៅការដើរតាមនៅបួនដំណាក់នេះៈ

១) យើងត្រូវតែដឹងពីដំណឹងល្អឲ្យបានច្បាស់។ យើងត្រូវតែយល់ដឹងពីដំណឹងល្អ ហើយបានទទួលនៅការផ្សាយដំណឹងល្អ។

២) យើងត្រូវតែបង្កើតេជីវិតយើងឲ្យមានទម្លាប់ការថ្វាយបង្គំជាប្រចាំនៅក្នុងការរស់នូវរបស់យើង។ គឺមានន័យថា យើងត្រូវការការដើរតាមនៃព្រលឹងវិញ្ញាណដោយផ្ដល់ខ្លួន ជាមួយការរស់នូវជាមួយនឹងព្រះជាម្ចាស់។

៣) យើងត្រូវតែមានការរីកចម្រើនលូតលាស់នៅក្នុងព្រះបន្ទូលរបស់ព្រះឲ្យបានល្អ (ដូចជាការសិក្សាព្រះគម្ពីរ) ពួកគេត្រូវរៀនពីការស្ដាប់បង្គាប់ ការថ្វាយដង្វាយដប់ហូតមួយ ការរក្សានៅថ្ងៃឈប់សម្រាក់ និង ជីវិតពេញដោយការថ្វាយបង្គំ។

៤) យើងត្រូវតែធ្វើឲ្យមានប្រយោជន៍សម្រាប់អ្នកដទៃ គឺជាម្នាក់ដែលបានបង្កើតអ្នកផ្សេងទៀត (តេត្រុសខ្សែទី១ ជំពូក២:៩) ដូចជា ផ្សាយដំណឹងល្អ ការឲ្យ ការធ្វើព័ន្ធកិច្ចជាដើម។

**ទីបី៖ ហេតុអ្វីបានជាយើងត្រូវបង្កើតសិស្ស?**

គោលបំណងរបស់ព្រះជាម្ចាស់គឺបង្កើតឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ហើយដើម្បីផ្សាយដំណឹងល្អទៅគ្រប់ទាំងមនុស្សទាំងអស់។ នៅក្នុងពាក្យផ្សេងទៀតគឺថា ចង្អុលទៅលើការផ្សាយដំណឹងល្អទៅគ្រប់ទាំងសាសន៍។ វាគឺជាការនៅកំរិតខ្ពស់បំផុតនៃការតាំងសញ្ញា។នៅក្នុងពាក្យផ្សេងទៀតគឺមានន័យថារីករាយអេម៉ាញូអែល(Immanuel)ដែលមានន័យថាព្រះគង់ជាមួយព្រះ។

ហើយវាមិនមែនមានន័យថាក្នុងពេលអនាគត់យើងត្រូវតែរីករាយជាមួយនឹងលោកិយ៍នោះទេ ប៉ុន្តែឥឡូវនេះយើងត្រូវតែមានសេចក្តីអំណរនៅក្នុងផែនដីនេះវិញ។ ព្រះគម្ពីរម៉ាកុសជំពូក១៦:២០ មានបន្ទូលថា *ឯពួកសិស្សគេចេញទៅប្រកាស់ប្រាប់នៅសព្វគ្រប់អន្លើ ដោយមានព្រះអម្ចាស់ ធ្វើការជាមួយ ទាំងបញ្ជាក់ព្រះបន្ទូល ដោយទីសំគាល់ ដែលកើតមកតាមក្រោយផង។*ព្រះជាម្ចាស់ទ្រង់ធ្វើការតាមរយៈការផ្សាយដំណឹងល្អរបស់ពួកសិស្សនិងសំដែងឲ្យឃើញពីទីសំគាល់ និង ការអះអាងនៃព្រះបន្ទូលរបស់ព្រះអង្គ។

នេះហើយជាសារៈសំខាន់នៃអេម៉ាញូអែល នៅក្នុងពាក្យផ្សេងទៀត គឺ ១ ការផ្សាយដំណឹងល្អត្រឹមត្រូវ។ ២ មានទីសំគាល់ (ការដោះខ្លួនចេញពីវិញ្ញាណអាក្រក់ មានការបង្ហាញពីការពឹងផ្អែកថ្មី ការព្យាបាលឲ្យជាពីពិសទាំងឡាយ)។៣)កិច្ចការពីព្រះបន្ទូលរបស់ព្រះគឺការបើកសម្តែងអំពីព្រះវិញ្ញាណបរិសុទ្ធ។នេះជាបំណងនៃការផ្សាយដំណឹងល្អក្នុងភាពបង្កើតសិស្ស។នេះហើយជាអាណាចក្ររបស់ព្រះយ៉ាងពិតប្រាកដ ហើយក៏ជាការស្តាឡើងវិញនៃរូបឆ្លុះរបស់ព្រះដែរ។ នៅក្នុងការសង្ខេបបីជំហាននេះមានះភាពជាសិស្ស ការផ្សាយដំណឹងល្អ និង ការស្តាឡើងវិញនៅរូបឆ្លុះរបស់ព្រះ។ បន្ទាប់យើងអាចរស់នៅក្នុងជីវិតដ៏បរិបូរណ៍បានហើយ។

បន្ទាប់មកតើជីវិតរបស់គ្រីស្ទបរិស័ទមានសន្តិភាពដោយរបៀបណា?ខ្ញុំចូលចិត្តដើរតាមជីវិតជាគ្រីស្ទបរិស័ទរបស់លោក ខាល់វីន(Calvin) ជាមួយនឹងការសង្ខេបបានយ៉ាងល្អមានដូចជា៖

១) អំពីគោលលិទ្ធិ- ដូចជាបញ្ញាតិដប់ប្រការ សេចក្តីអធិស្ថានលំនាំព្រះអម្ចាស់ និង គោលលិទ្ធិនៃពួកសាវ័ក។

២) ជីវិត- (ក) ការស្តាប់បង្គាប់ដោយការបន្ទាប់ខ្លួន (ខ) ការបដិសេធខ្លួនឯង (គ) ការលីឈើឆ្កាងតាមព្រះយេស៊ូវ (ឃ) ជីវិតរស់នៅដោតត្រឹមត្រូវក្នុងជីវិតបច្ចុប្បន្ន (ង) មានសេចក្តីសង្ឃឹម។

ភាពជាសិស្សគឺត្រូវមានការរស់នៅប្រាំចំនុចនេះ។យើងត្រូវការការលះបង់ច្រើនចំពោះការរស់នៅទាំងនេះពីព្រោះការធ្វើការខាងសាច់ឈាមគឺវាតឹងរឹងណាស់នៅក្នុងយើង។បងប្អូនបរិសុទ្ធជាទិស្រឡាញ់ ព្រះវិហារនៃព្រះគឺជាការជួបជុំសិស្សដែលពិតប្រាកដ។ដើម្បីធ្វើជាសិស្សព្រះជាម្ចាស់គឺយើងត្រូវតែលះបង់ច្រើន ដោយសារតែពួកគេគឺជាសិស្សរបស់ព្រះជាម្ចាស់ មិនមែនជាសិស្សនៃមនុស្សលោកទេ។ ក្នុងន័យផ្សេងទៀតគឺថាយើងត្រូវតែដាក់ចិត្តដាក់កាយជាអ្នកគ្រាប់តាមនៅរូបឆ្លុះរបស់ព្រះ។ក៏ដូចជាលោក ខាល់វីន(Calvin)បានចង្អុលបង្ហាញដោយយើងគួតែផ្ចង់ទៅលើការ

ស្តាប់បង្គាប់ដោយការបន្ទាប់ខ្លួនការបដិសេធខ្លួនឯង ការលីឈើឆ្កាងតាមព្រះជាម្ចាស់ ការចូលរួមទៅក្នុងជីវិតបច្ចុប្បន្ន និងជីវិតមានក្តីសង្ឃឹម។ នៅក្នុងចំនុចផ្សេងទៀត គឺបានចង្អុលបង្ហាញ ពីព្រះពរទាំងប្រាំបី នៅក្នុងព្រះគម្ពីរម៉ាថាយ ជំពូក ប្រាំ។ *សូមឲ្យព្រះគុណនៃព្រះបាននៅជាមួយនឹងអ្នកទាំងអស់គ្នាក្នុងឆ្នាំថ្មីនេះ។អាម៉ែន!*

**មេរៀនអធិប្បាយទី1ង្វាយដ៏ពិត (លោកបណ្ឌិត វ៉ាយ យ៉ុង ជុន)**(True Offering) by Rev. White Young)

១កាលមុនបុណ្យរំលង៦ថ្ងៃ នោះព្រះយេស៊ូវយាងមកដល់ដល់ភូមិបេថានី ជាកន្លែងឡាសារនៅ គឺជាអ្នកដែលទ្រង់ប្រោសអោយរស់ពីស្លាប់ឡើងវិញ ២នៅទីនោះគេរៀបចំព្រះស្ងោយថ្វាយទ្រង់ ហើយនាងម៉ាថាក៏ខ្វល់ខ្វាយបំរើ អែឡាសារ គាត់នៅក្នុងពួកអ្នកដែលអង្គុយនៅតុ ជាមួយនឹងទ្រង់ដែរ ៣នោះនាងម៉ារាយកប្រេងក្រអូបទេព្វិរូសុទ្ធ១នាលិ មានតំលៃណាស់ មកចាក់លាបព្រះបាទទ្រង់ រួចយកសក់នាងជូត ក្លិនក្រអូបនោះក៏សាយឡើងពេញក្នុងផ្ទះ ៤ ដូច្នេះពួកសិស្សទ្រង់ម្នាក់ឈ្មោះយូដាស-អីស្ការីយ៉ុត ជាកូនស៊ីម៉ូនដែលរៀបនឹងបញ្ជូនទ្រង់ក៏និយាយឡើងថា ៥ម្តេចឡើយក៏មិនបានលក់ប្រេងក្រអូបនេះជា*តំ*លៃ៦០រៀលដើម្បីចែកអោយដល់មនុស្សក្រីក្រវិញ ៦ វានិយាយដូច្នោះ មិនមែនដោយវាយកចិត្តទុកដាក់នឹងមិនុស្សក្រីក្រទេ គឺដោយព្រោះវាជាចោរ វាកាន់ថង់ប្រាក់ ហើយក៏លួចយករបស់ដែលដាក់នៅក្នុងថង់នោះផង ៧ព្រះយេស៊ូវមានបន្ទូលថា កុំអោយធ្វើនាងឡើយ ដ្បិតនាងបានទុកប្រេងក្រអូបនេះ សំរាប់ដល់ថ្ងៃបញ្ចុះខ្មោចខ្ញុំ ៨ អែអ្នករាល់គ្នា តែងតែមានពួកអ្នកក្រនៅជាមួយជាដ៏រាប តែខ្ញុំមិននៅជាមួយជាដ៏រាបទេ។(យ៉ូហាន១២:១-៨)

## សេចក្តីផ្តើម

នៅក្នុងជីវិតគ្រីស្ទបរិស័ទ ដើម្បីរៀនពីជីវិតនៃការថ្វាយដង្វាយដ៏ពិត គឺសំខាន់ណាស់ ព្រោះវាឆ្លុះបញ្ចាំងពីជំនឿពិត។ នៅពេលយើងសង្កេតមើលអាយុកាលនៃដង្វាយនៅក្នុងយើង នោះយើងអាចវាយតម្លៃកំរិតនៃជំនឿរបស់យើងបានយ៉ាងល្អ។ទោះបីជានរណាម្នាក់ត្រូវបានគេទទួលស្គាល់ថាជាគ្រីស្ទបរិស័ទល្អបំផុតក៏ដោយ ប្រសិនបើគាត់មិនស្មោះត្រង់ក្នុងអាកប្បកិរិយានៃការថ្វាយដង្វាយត្រឹមត្រូវទេ គាត់នឹងត្រូវជួបការលំបាកខ្លាំង។ ហេតុអ្វី? ពីព្រោះជីវិតនៃដង្វាយរបស់គាត់ បង្ហាញពីសេចក្តីជំនឿរបស់គាត់។ តើវាមានន័យថា គាត់បានថ្វាយប្រាក់ជាច្រើនដល់ព្រះរឺ? ទេតើវាជាអ្វី? យោងទៅតាមបទគម្ពីរ លុយជាច្រើនមិនមែនជាការថ្វាយច្រើននោះទេ ហើយប្រាក់តិចតួចក៏មិនមែនជាការថ្វាយតិចតួចដែរ។ លក្ខណៈវិនិច្ឆ័យសមហេតុផលគឺខុសគ្នានឹងស្តង់ដារព្រះគម្ពីរ។

ម៉ាកុស ១២:៤១-៤៤ នៅគ្រាមួយព្រះយេស៊ូវទ្រង់គង់ទល់មុខនឹងឃ្លាំងនៅក្នុងសាលាប្រជុំ។ មានបុរសអ្នកមានម្នាក់ដាក់មាស ប្រាក់ជាច្រើនចូលទៅក្នុងឃ្លាំង ប៉ុន្តែមានស្ត្រីមេម៉ាយក្រីក្រម្នាក់បានដាក់ប្រាក់តែ

ពីស្លឹងដែលត្រូវជាកន្លះសេនចូលក្នុងឃ្លាំង ។វាពិតជាកំសត់ខ្លាំងណាស់។ បន្ទាប់មកព្រះយេស៊ូវបានបង្រៀនដល់សិស្សរបស់ទ្រង់អំពីដង្វាយពិត។ ព្រះយេស៊ូវបានប្រកាសថា ស្ត្រីនេះបានថ្វាយដង្វាយច្រើនជាងអ្នកមាន។ ហេតុអ្វី? ដោយសារតែអ្នកមានយកពីរបស់ជាសំណល់របស់គាត់ចូលទៅក្នុងឃ្លាំង ប៉ុន្តែស្ត្រីមេម៉ាយក្រនេះបានយករបស់ដែលនាងមានទាំងប៉ុន្មានសំរាប់ចិញ្ចឹមជីវិតខ្លួនមកថ្វាយវិញ។ នៅចំពោះព្រះភក្ត្ររបស់ព្រះ ការថ្វាយច្រើន កើតឡើងពីរការលះបង់ និងសេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះ។ នៅអត្ថបទថ្ងៃនេះសង្កត់ធ្ងន់លើសេចក្តីពិតនេះម្តងទៀត ដោយបង្រៀនពីការថ្វាយដ៏ពិតប្រាកដដល់កាន់យើង។

## ក.តើដង្វាយដ៏ពិតគឺជាអ្វី?

អត្ថបទព្រះគម្ពីរបង្ហាញពីព្រឹត្តិការណ៍ជាក់ស្តែងមួយសំរាប់យើង។ ក្រោយពីព្រះយេស៊ូវបានប្រោសឡាសារដែលបានស្លាប់ចេញពីផ្នូរ នោះបងស្រីរបស់គាត់ម៉ាថា និងម៉ារាបានរៀបចំពិធីជប់លៀងមួយសម្រាប់ព្រះយេស៊ូវនិងពួកសិស្សរបស់ទ្រង់នៅក្នុងផ្ទះ។ បន្ទាប់មកម៉ារាបានយកប្រេងក្រអូបមកចាក់លាបព្រះបាទទ្រង់ ហើយបានយកសក់នាងជូតដោយទឹកភ្នែករបស់នាង។ បន្ទាប់មកយ៉ូដាសអ៊ីស្ការីយ៉ុតបានរិះគន់ការលះបង់របស់ម៉ារី។ *⁴ ដូច្នេះពួកសិស្សទ្រង់ម្នាក់ឈ្មោះយូដាស-អ៊ីស្ការីយ៉ុត ជាកូនស៊ីម៉ូន ដែលរៀបនឹងបញ្ជូនទ្រង់ក៏និយាយឡើងថា ⁵ ម្តេចឡើយក៏មិនបានលក់ប្រេងក្រអូបនេះជាតំលៃ៦០រៀល ដើម្បីចែកអោយដល់មនុស្សក្រីក្រវិញ ⁶ វានិយាយដូច្នោះ មិនមែនដោយវាយកចិត្តទុកដាក់នឹងមិនុស្សក្រីក្រទេ គឺដោយព្រោះវាជាចោរ វាកាន់ថង់ប្រាក់ ហើយក៏លួចយករបស់ដែលដាក់នៅក្នុងថង់នោះផង ⁷ព្រះយេស៊ូវមានបន្ទូលថា កុំអោយធ្វើនាងឡើយ ដ្បិតនាងបានទុកប្រេងក្រអូបនេះ សំរាប់ដល់ថ្ងៃបញ្ចុះខ្មោចខ្ញុំ ⁸ អែអ្នករាល់គ្នា តែងតែមានពួកអ្នកក្រនៅជាមួយជាដ៏រាប តែខ្ញុំមិននៅជាមួយជាដ៏រាបទេ។* - នៅកន្លែងនេះយើងរកឃើញការពិត នូវអ្វីទៅជាដង្វាយពិត និងការលះបង់ពិតប្រាកដ។

- ក្នុងជីវិតរបស់យើង ជានិច្ចកាលនៅពេលយើងថ្វាយបង្គំព្រះជាម្ចាស់ យើងត្រូវចងចាំការបង្រៀននេះដល់យើង។ តើការលះបង់ពិតប្រាកដគឺជាអ្វី?

### ១ គឺជាការថ្វាយដង្វាយរបស់យើង ក្នុងនាមជាអ្នកតំណាងអោយគ្រប់របស់ទាំងអស់របស់យើង ចំពោះព្រះអម្ចាស់។

នៅទីនេះម៉ារីបានថ្វាយប្រេងក្រអូបដ៏មានតម្លៃបំផុតមួយនាលិរបស់នាងធ្វើពីទេព្វិរូសុទ្ធដល់ព្រះអម្ចាស់។ តើវាមានតម្លៃប៉ុន្មាន? វាមានចំនួន ៣០០ ដេណារ។ (ប្រហែលប្រាក់ខែចំនួនមួយឆ្នាំរបស់យើង)បន្ទាប់មកព្រះអម្ចាស់វាយតម្លៃថានាងបានថ្វាយដង្វាយជាច្រើន។ តង្វាយពិតគួរតែរួមបញ្ចូលទាំងចិត្តដែលគាត់បានថ្វាយដូចជាអេបិល។

ឧទាហរណ៍៖ កាអ៊ីននិងអេបិលបានថ្វាយដល់ព្រះនៅអាសនៈតែមួយកន្លែងតែមួយពេលតែមួយនិងវិធីសាស្រ្តដូចគ្នា ។ (គ្រាប់ធញ្ញជាតិនិងចៀម) ប៉ុន្តែលទ្ធផលរបស់ពួកគេគឺខុសគ្នា។ *លោកុប្បត្តិ១៤:៤-៥ថែង*

*ថា«ហើយអេបិលក៏បានធ្វើដូចគ្នា គឺគាត់យកកូនជាដំបូង១ពីហ្វូងសត្វមកថ្វាយ ព្រមទាំងខ្លាញ់វាផង រួចព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យចំពោះអេបិល នឹងដង្វាយរបស់គាត់ ៥តែមិនសព្វព្រះហឫទ័យចំពោះដង្វាយចំពោះកាអ៊ីនទេ នោះកាអ៊ីនក៏ក្តៅក្រហាយ ហើយឡើងទឹកមុខក្រញូវ។*
ដូច្នេះយើងត្រូវតែពិនិត្យមើលការថ្វាយរបស់យើងនៅក្នុងពេលវេលាថ្វាយបង្គំពេលសរសើរនិងក្នុងកិច្ចបំរើរបស់យើង។

**២.វាគឺដើម្បីលះបង់ខ្លួនយើងទៅចំពោះព្រះអម្ចាស់ អ្នកជិតខាងរបស់យើង**
យូដាបានរិះគន់សកម្មភាពរបស់ព្រះយេស៊ូវដែលបានទទួលយកដង្វាយចាក់ប្រេងរបស់ម៉ារី។ ការលះបង់ពិសេសរបស់នាងមានចរិតពីរប្រភេទ, ទី១នាងបានថ្វាយខ្លួនដ (ល់ព្រះយេស៊ូ សក់របស់នាងត្រូវបានគេ - ប្រើសម្រាប់ព្រះអម្ចាស់។  ទី២នាងបានជូនអំណោយល្អបំផុតដល់ព្រះអម្ចាស់។ (- ការថ្វាយដង្វាយតំលៃចំនួន ៣០០ ឌីណារីដល់ ព្រះអម្ចាស់។ វាហាក់ដូចជាគ្មានន័យទេសម្រាប់ទឹកអប់អាចរលាយបាត់ភ្លាមៗនេះ។ ព្រះ  យេស៊ូវមានព្រះ  បន្ទូលថា៖ «ទុក ឲ្យ នាងធ្វើតាមចិត្តនាងទៅដ្បិតនាងបានទុកប្រេងក្រអូបនេះ សំរាប់ដល់ថ្ងៃបញ្ចុះខ្មោចខ្ញុំ។នៅទីនេះយើងត្រូវរៀនថា ការថ្វាយដ៏ពិតប្រាកដ គួរតែត្រូវបានថ្វាយដល់ព្រះគ្រីស្ទ យេស៊ូវផ្ទាល់។

**៣. វាគួរតែផ្តោតលើឈើឆ្កាងរបស់ព្រះគ្រីស្ទដែលជាព្រះអម្ចាស់នៃការប្រោសលោះ**
ព្រះអម្ចាស់មានព្រះបន្ទូលថា ញុំ។ អ្នកក្រីក្រនៅជាមួយអ្នករហូតរីឯអ្នករាល់គ្នាមិននៅជាមួយខ្ញុំរហូតទេ។ អ្នករាល់គ្នា តែងតែមានពួកអ្នកក្រនៅជាមួយជាដ៏រាប តែខ្ញុំមិននៅជាមួយជាដ៏រាបទេ។

ក តើតង្វាយពិតគឺជាអ្វី? តង្វាយពិតគឺជាការថ្វាយបង្គំពិត។ ដូច្នេះបុរសដែលបានសង្គ្រោះពីអំពើបាបដ៏សែនវេទនារបស់គាត់គួរតែថ្វាយខ្លួនដល់ព្រះដើម្បីប្រកាសពីសេចក្តីសង្គ្រោះដល់ពិភពលោក។ យូដាមិនអាចយល់អត្ថន័យពិតនៃការថ្វាយបង្គំបានទេពីព្រោះគាត់មិនបានកើតជាថ្មីនៅក្នុងជីវិតរបស់គាត់ទេ។ ចុះយ៉ាងណាចំពោះពួកផារិស៊ី? ហើយពួកគេក៏មិនអាចយល់ពីការថ្វាយពិតប្រាកដដែរពីព្រោះពួកគេមិនបានកើតជាថ្មីនៅក្នុងជីវិត។
ខ. យើងគួរតែផ្តល់ជូនខ្លួនយើងលុយដ៏មានតម្លៃនិងពេញមួយជីវិតរបស់យើងដល់ព្រះការសង្គ្រោះរបស់យើងគ្រាន់តែជាការផ្តល់ជូនការផ្តល់ជូនពិតប្រាកដប៉ុណ្ណោះ។ អតីត :ក្នុងនាមជាវីនស្តូនដែលជាអ្នកផ្សព្វផ្សាយសាសនាអាហ្វ្រិកដំបូងគេដែលបានថ្វាយតង្វាយរបស់គាត់នៅក្នុងពេលវេលាគោរពបូជាដោយសារគាត់ក្រីក្រខ្លាំងណាស់។ ពេលថង់យញ្ញបូជាមកជិតគាត់ស្រាប់តែគាត់ដាក់ក្បាលចូលទៅក្នុងកាបូប។ មនុស្សគ្រប់គ្នាមានការភ្ញាក់ផ្អើលចំពោះសកម្មភាពរបស់គាត់។ បន្ទាប់មកគាត់បានសារភាពប្រាប់ក្រុមជំនុំដោយស្មោះត្រង់។ ទោះបីខ្ញុំគ្មានប្រាក់ក៏ដោយខ្ញុំចង់ដាក់ជីវិតរបស់ខ្ញុំទាំងមូលទៅព្រះជំនួសការថ្វាយ។ ទីបំផុតគាត់បានលះបង់ខ្លួនឯងដើម្បីទៅអារីហ្វ្រើជាអ្នកផ្សព្វផ្សាយសាសនាដល់ព្រះ។ នេះគឺ

ជាតង្វាយពិត។ខ្ញុំបានសង្កេតមើលព្រះវិហារកម្ពុជាអស់រយៈពេល ១៣ ឆ្នាំ។ មនុស្សជាច្រើនរស់នៅជាទាសករលុយនិងលោភលន់ក្នុងជីវិតរបស់គាត់។ លុយគឺជារូបចម្លាក់របស់ពួកគេ។ នៅក្នុងជីវិតគ្រីស្ទបរិស័ទប្រសិនបើគាត់មិនត្រូវបានផ្លាស់ប្តូរទៅជាល្បែងព្រះគម្ពីរនោះគាត់គ្មានសង្ឃឹមទេនាពេលអនាគត។ ប៉ុន្តែប្រសិនបើគាត់ភ្ញាក់ដឹងខ្លួនហើយធ្វើតាមការសន្យារបស់គាត់ចំពោះព្រះគាត់នឹងក្លាយជាមនុស្សអស្ចារ្យម្នាក់។ ដូច្នេះខ្ញុំសង្កត់ធ្ងន់លើរឿង ៤ យ៉ាងចំពោះគ្រីស្ទបរិស័ទគ្រប់រូបដើម្បីរក្សា ១ (២ជីវិតធម្មការ (ចូលរួមស្មោះត្រង់ក្នុងការថ្វាយបង្គំព្រះ ៣ (៤ដល់ព្រះដោយស្មោះត្រង់ ១០ភាគ ១យដង្វាយ ថ្វា (ការផ្សាយដំណឹងល្អ។ ល។

ម៉ាឡាគី ៣និយាយថា ១០:" ចូរយកមួយភាគដប់ពេញទៅក្នុងឃ្លាំងដើម្បី ឲ្យ មានអាហារនៅក្នុងផ្ទះ។ ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា៖ «ប្រសិនបើអ្នករាល់គ្នាមិនចង់បើកបង្អួចស្ថានបរមសុខអោយអ្នករាល់គ្នាទេនោះយើងនឹងអោយពរដល់អ្នករាល់គ្នារហូតដល់លែងត្រូវការតទៅទៀត។តើចោរជាអ្វី? គាត់គឺជាបុរសដែលព្រងើយកន្តើយចំពោះដង្វាយមួយភាគក្នុងដប់ដើម្បីថ្វាយព្រះអម្ចាស់។តើការសន្យារបស់ព្រះជាអ្វី? វាគឺជាការចាក់ប្រាក់ដ៏អស្ចារ្យដល់ពួកយើងក្នុងមួយជីវិតរបស់យើង។

## សេចក្តីបញ្ចប់

ការលះបង់ពិតប្រាកដនឹងនាំមកនូវព្រឹត្តិការណ៍ដ៏អស្ចារ្យទាំងនោះ។ ព្រះអម្ចាស់នឹងសំដែងសិរីរុងរឿងអ្នកថ្វាយព្រះអង្គផ្ទាល់នឹងទទួលព្រះគុណដ៏អស្ចារ្យពីព្រះជាម្ចាស់។ ឥឡូវនេះព្រះអម្ចាស់កំពុងស្វែងរកដង្វាយពិតអ្នកថ្វាយបង្គំពិតនៅលើផែនដី។ ទោះបីអ្នកជាអ្នកក្រខ្លាំងអ្នកអាចផ្តល់តង្វាយដ៏អស្ចារ្យដល់ព្រះដ៏មានព្រះជន្មរស់។

ប្រសិនបើអ្នកចង់ក្លាយជាអ្នកមាននៅគ្រប់តំបន់ក្នុងជីវិតរបស់យើង។ សូមធ្វើតាមការណែនាំក្នុងព្រះគម្ពីរ "ថ្វាយដង្វាយដោយចិត្តស្មោះដល់ព្រះ។ "ចងចាំការសន្យានិងប្រកួតប្រជែងវានៅក្នុងជីវិតរបស់អ្នក។ បើអ្នកចង់ក្លាយជាអ្នកមានចូរធ្វើតាមបញ្ញត្តិនេះ។ ចាប់ពីពេលនេះទៅបោះចោលដើម្បីទទួលបានកាដូដោយឥតគិតថ្លៃ។ ឈរនៅចំពោះព្រះ។ ស្វែងរកតម្រូវការរបស់អ្នកចំពោះព្រះ។ សូមអោយព្រះគុណរបស់ព្រះជាម្ចាស់ស្ថិតនៅជាមួយអ្នកក្នុងការប្រតិបត្តិតាមបទបញ្ជានេះ។

## សូមអធិស្ឋាន

ព្រះវរបិតាសួគ៌ យើងសូមអរគុណចំពោះសេចក្តីពិតដ៏អស្ចារ្យការផ្តល់ជូនពិតនិងពរជ័យពិតធ្វើឱ្យយើងសម្រេចចិត្តគោរពតាមបទបញ្ជារបស់ទ្រង់សម្រាប់សិរីល្អរបស់ទ្រង់។ផ្តល់នូវព្រះគុណរបស់អ្នកដើម្បីគោរពតាមពាក្យរបស់អ្នក។ទោះបីយើងក្រក្នុងជីវិតក៏ដោយធ្វើឱ្យយើងក្លាយជាអ្នកផ្តល់អ្វីៗជាច្រើនដល់អ្នកជិតខាងនិងពិភពលោកទាំងមូល។ ខ្ញុំអធិស្ឋានគ្រប់ការទាំងអស់នៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

## មេរៀនទី 2 អត្ថន័យនៃពិធីបុណ្យជ្រមុជទឹក (The Meaning of Baptism)

*២០ គឺក្នុងខណៈដែលសេចក្ដីអត់ធ្មត់របស់ព្រះ បានរង់ចាំក្នុងជំនាន់លោកណូអេ កាលលោកកំពុងធ្វើទូកធំ ហើយនៅក្នុងទូកនោះមានមនុស្សតែបន្តិច គឺ៨នាក់ប៉ុណ្ណោះដែលបានរួចដោយសារទឹក ២១ដែលទឹកនោះហើយ ជាគំរូពីបុណ្យជ្រមុជ ដែលជួយសង្គ្រោះយើងសព្វថ្ងៃនេះ មិនមែនជាការសំអាតក្អែលរបស់រូបសាច់ទេ គឺជាសេចក្ដីសន្មតិរបស់បញ្ញាចិត្តជ្រះថ្លាចំពោះព្រះវិញ ដោយសារព្រះយេស៊ូវគ្រីស្ទទ្រង់មានព្រះជន្មរស់ឡើងវិញ។* (ព្រះគម្ពីរពេត្រុសទី១ជំពូក៣:២០-២១)

### សេចក្ដីផ្ដើម

ខ្ញុំថ្វាយសិរីល្អទៅព្រះជាម្ចាស់ សម្រាប់ព្រះគុណដ៏អស្ចារ្យរបស់ទ្រង់ដែលមានសម្រាប់សហរដ្ឋអាមេរិក ពីព្រោះកូនស្រីរបស់ខ្ញុំបានប្រសើរឡើងដោយសារព្រះគុណនៃព្រះជាម្ចាស់ និងថវិកាព័ន្ធកិច្ចបានកើតឡើងក៏ដោយសារការអធិស្ឋានច្រើន តាមរយៈអ្នកបរិច្ចាកម្នាក់។ ជាការពិតខ្ញុំមានគម្រោងសាងសង់នៅមជ្ឈមណ្ឌលព័ន្ធកិច្ច CEMF នៅភ្នំពេញជាមួយនឹងទឹកប្រាក់ ពីរបីលានដុល្លា ប៉ុន្តែខ្ញុំមិនបានធ្វើវាទេ។ ខ្ញុំក៏បានទទួលនៅថវិការខ្លះរួចខ្ញុំបានសម្រាច់ចិត្តសាងសង់មជ្ឈមណ្ឌលអប់រំនៅប៉ៃលិនវិញពីព្រោះអ្នកបរិចាកចង់សាងសង់មជ្ឈមណ្ឌលអប់រំសម្រាប់ជាការចងចាំនៅអនុស្សាវរីយ៍មួយហើយនិងលោកគ្រូរិទ្ធីបានអធិស្ឋានសម្រាប់មជ្ឈមណ្ឌលអប់រំនេះដែរ។ ដូច្នេះចាប់ពីខែមិនារហូតដល់ខែចុងខែមិថុនា ឆ្នាំ២០២០ យើងនឹងបញ្ចប់គម្រោងនៃការសាងសង់សម្រាប់ការផ្សាយដំណឹងល្អនៅគ្រប់ភូមិនៃខេត្តប៉ៃលិននេះ។ ឆាប់ៗនេះក្រុមព័ន្ធកិច្ចនៃការជួបប្រជុំអ្នកផ្សាយដំណឹងល្អនឹងបានបញ្ចប់នៅខេត្តប៉ៃលិននេះហើយវានឹងបានចាប់ផ្ដើមដោយលោកគ្រូ ជឹម រិទ្ធី វិញ។ នៅក្នុងខណៈនេះព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំយល់ដឹង ពីសេចក្ដីពិតដ៏អស្ចារ្យ អំពីការផ្សាយដំណឹងល្អនិងមូលដ្ឋានគ្រឹះនៃសេចក្ដីពិតនៅក្នុងចិត្តខ្ញុំវិញ។ក្នុងចំណោមនោះខ្ញុំបានយល់ពីអត្ថន័យពីការជ្រមុជទឹកតាមរយៈការបង្រៀនរបស់លោកពេត្រុស។

លោកសាវ័កប៉ុលបានយល់ថាការឆ្លងកាត់សមុទ្រក្រហមគឺជាការចង្អុលពីការជ្រមុជទឹកពីព្រោះជនជាតិអ៊ីស្រាអែលបានឆ្លងកាត់សមុទ្រក្រហមដោយពួកគេបានទទួលបទពិសោធន៍ពីសេចក្ដីស្លាប់របស់ពួកគេ ហើយបានរស់ឡើងវិញដោយជំនឿ គឺដូចជាការសុគត់របស់ព្រះសង្គ្រោះនិងការរស់ឡើងវិញ។ វាមានន័យថា ជានិមិត្តសញ្ញាដែលបានក្លាយទៅជាការពិត។

ទោះបីយ៉ាងណាក៏ដោយសាវ័កពេត្រុសបានយល់ដឹងពីព្រឹត្តការណ៍នៃទឹកជំនន់លោកណូអេគឺបង្ហាញពីការជ្រមុជទឹកនៃប្រជាជនរបស់គាត់។ដូចជាគ្រួសារលោកណូអេចំនួន៨នាក់បានរស់ចេញពីទឹកជំនន់ដោយសារទូក។ដូច្នេះយើងក៏បានសង្គ្រោះឲ្យរួចពីអំពើបាបដ៏អាក្រក់ដែរ។ដូចជាយើងជឿថាយើង

បានទទួលបទពិសោធន៍ពីសេចក្ដីស្លាប់ និងពីការរស់ឡើងវិញដែរ។ព្រះគម្ពីររ៉ូមជំពូក៦:៣-៤ មានបន្ទូលថា *[៣]តើអ្នករាល់គ្នាមិនដឹងទេឬអី ថា យើងទាំងប៉ុន្មានដែលបានទទួលបុណ្យជ្រមុជក្នុងព្រះយេស៊ូវគ្រីស្ទ នោះគឺបានទទួលជ្រមុជក្នុងសេចក្ដីសុគតនៃទ្រង់ដែរ [៤]ដូច្នេះយើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្ដីស្លាប់ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មីដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញដោយសារសិរីល្អនៃព្រះវបិតាដែរ។*

## នៅថ្ងៃនេះយើងចង់ឲ្យគិតតើពិធីបុណ្យជ្រមុជទឹកមានន័យយ៉ាងដូចម្ដេចនៅក្នុងគ្រីស្ទបរិស័ទ?

ជាដំបូងពិធីបុណ្យជ្រមុជទឹកគឺជាព្រឹត្តិការណ៍ដំបូង (ជំហានទមួយ) ដើម្បីសង់ក្រុមជំនុំនៅក្នុងលោកិយ៍នេះ។ព្រះជាម្ចាស់បានសង្កត់ធ្ងន់រួចមកពួកសាវ័កផ្សាយដំណឹងល្អហើយត្រូវតែធ្វើពិធីបុណ្យជ្រមុជទឹកឲ្យដោយនៅក្នុងព្រះនាមព្រះត្រៃឯក ក្នុងព្រះគម្ពីរម៉ាថាយ ជំពូក២៨:១៩មានបន្ទូលថា *[១៩]ដូច្នេះចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធចុះ* ។តើអ្វីដែលជាសកម្មភាពដំបូងរបស់ក្រុមជំនុំត្រូវតែធ្វើសម្រាប់អ្នកជឿ?វាគឺជាការផ្ទុកផ្ដាក់ជ្រមុជទឹកឲ្យគាត់។

- យើងត្រូវតែទទួលស្គាល់កថាក្រុមជំនុំគឺជាការជួបប្រជុំក្រុមមនុស្សដែលបានទទួលការជ្រមុជទឹកនៃព្រះវិញ្ញាណបរិសុទ្ធ និង យើងត្រូវតែទទួលស្គាល់ថា គ្រីស្ទបរិស័ទត្រូវតែបានជ្រមុជទឹកដោយទឹកជាសាធារណៈ។ ដូច្នេះយើងត្រូវដឹងថាបើគ្មានការជ្រមុជទឹកនៃព្រះវិញ្ញាណបរិសុទ្ធទេ នោះក៏គ្មានសេចក្ដីសង្គ្រោះដែរហើយប្រសិនបើគ្មានការជ្រមុជទឹកដោយទឹក នោះក៏គ្មានការធានាអះអាងហើយក៏គ្មាននៅភាពត្រឹមត្រូវនៅក្នុងជីវិតជាគ្រីស្ទបរិស័ទពេញលេញដែ។នេះជាសញ្ញាពិតប្រាកដនៃសេចក្ដីសង្គ្រោះរបស់យើង ដូចជាការសំគាល់ខ្លះដែលមានដូចជា ការកាត់ស្បែក និងសញ្ញាឥន្ទនូជាដើម។

ដូច្នេះនៅពេលដែលយើងជឿព្រះគ្រីស្ទជាព្រះរបស់យើងយើងត្រូវតែស្នើរសុំធ្វើពិធីជ្រមុជទឹកដោយទឹកដូចជាការតាំងសញ្ញានៃសេចក្ដីសង្គ្រោះរបស់ក្រុមជំនុំ។

ការធ្វើពិធីបុណ្យជ្រមុជទឹកឲ្យទារក គឺចង្អុលបង្ហាញពីពិធីជ្រមុជទឹកថា ឪពុកម្ដាយដែលជាគ្រីស្ទបរិស័ទត្រូវមានការទទួលខុសត្រូវជំនួសសេចក្ដីជំនឿនៃកូនរបស់ពួកគេដើម្បីបង្រៀនឲ្យត្រឹមត្រូវទៅតាមការតាំងសញ្ញានៃជីវិត។

ដូច្នេះយើងឲ្យសំណួរ៤ ទៅពួកគេហើយពួកគេត្រូវឆ្លើយជំនួសទៅចំពោះព្រះ។ ហើយបន្ទាប់មកទារកនឹងធំឡើង គេនឹងត្រូវទទួលសេចក្ដីជំនឿម្ដងទៀតទៅចំពោះព្រះដោយខ្លួនគេផ្ទាល់ ជាមួយបញ្ញាចិត្តរបស់គេ។បន្ទាប់មកពិធីជ្រមុជទឹកនឹងមានឥទ្ធិពលទៅចំពោះពួកគេ។ប្រសិនបើក្មេងៗដែលបានធ្វើពិធីរួចត្រូវបាត់បង់ជីវិតដោយគ្រោះថ្នាក់ណាមួយ នោះយើងជឿថាពួកគេនឹងទទួលបានការសង្គ្រោះឲ្យរួចពីអំពើបាបដ៏អាក្រក់បាន ពីព្រោះគេគឺជារាស្ត្រនៃការតាំងសញ្ញា។

ដូច្នេះយើងគោរពការធ្វើបុណ្យជ្រមុជទឹកនៅក្នុងជីវិតផ្ទាល់ខ្លួន។ យើងទទួលស្គាល់ថា ថ្ងៃនៃពិធីជ្រមុជទឹកគឺប្រសើជាងថ្ងៃខួបកំណើតរបស់យើង។

**ទីពីរ៖ ពិធីជ្រមុជទឹកគឺជាការស្នើរសុំថា ជាសេចក្តីសន្មតិរបស់បញ្ញាចិត្តដ៏ជ្រះថ្លាចំពោះព្រះវិញ**

ព្រះគម្ពីរពេត្រុសទី១ជំពូក៣:២១ចែងថា៖

២១ដែលទឹកនោះហើយ ជាគំរូពីបុណ្យជ្រមុជ ដែលជួយសង្គ្រោះយើងសព្វថ្ងៃនេះ មិនមែនជាការសំអាតក្អែលរបស់រូបសាច់ទេ គឺជាសេចក្តីសន្មតិរបស់បញ្ញាចិត្តជ្រះថ្លាចំពោះព្រះវិញដោយសារព្រះយេស៊ូវគ្រីស្ទទ្រង់មានព្រះជន្មរស់ឡើងវិញ។

អត្ថន័យនៅក្នុងខរនេះគឺបង្ហាញពីគ្រីស្ទបរិស័ទមាននៅបញ្ញាចិត្តដ៏ល្អហើយនេះជាក្បួនខ្នាតមួយសម្រាប់ឲ្យដឹងពីការល្អនិងការអាក្រក់ ព្រះនិងសាតាំង ពន្លឺនិងងងឹត។

នៅទីនេះសាវ័កពេត្រុសបានសង្កត់ធ្ងន់ពីអត្ថន័យនៃពិធីជ្រមុជទឹកដែលជាវិជ្ជមានបន្ថែមទៀត។ ហេតុអ្វី? ដោយសារតែពិធិជ្រមុជទឹកមិនមែនជាសញ្ញាធម្មតាប៉ុណ្ណោះទេក៏ប៉ុន្តែជាសញ្ញានៃជីវិតសម្រាប់សេចក្តីសង្គ្រោះ។ *តើពិធិជ្រមុជទឹកជាអ្វី?*

វាគឺបានប្រើជាមុខងារនៃសតិសប្បជ្ជនៈល្អ។ នៅទីនេះបញ្ញាចិត្តគឺជាក្បួនខ្នាតសម្រាប់ដឹងនៅអ្វីល្អនិងអ្វីទៅខុស។ ស្តេចដាវិឌបានសារភាពថា វាគឺជាការស្មោះត្រង់ចិត្ត។ លោកប៉ុកបានបង្រៀនថា យើងត្រូវតែប្រុងប្រយ័ត្ន ដើម្បីរក្សានៅបញ្ញាចិត្តល្អរបស់យើង ដោយដារតែមនុស្សជាច្រើនបានធ្វើឲ្យបាក់បែកនៅមុខតំណែងរបស់បញ្ញាចិត្តដ៏ល្អនៅក្នុងជីវិតរបស់គាត់។ ដូច្នេះជីវិតរបស់គ្រីស្ទបរិស័ទ គឺត្រូវដើរតាមព្រះបន្ទូលរបស់ព្រះ ត្រូវស្វែងរកនគររបស់ព្រះនិងបំណងព្រះរាជហរទ័យនៃព្រះដោយបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ*តើគ្រីស្ទបរិស័ទជាអ្វី?* គឺជាម្នាក់ដែលមានបញ្ញាចិត្តជ្រះថ្លា។ ដូចជាយើងបានកើតម្តងទៀតក្នុងព្រះវិញ្ញាណបរិសុទ្ធហើយនិងសេចក្តីពិត។ បញ្ញាចិត្តរបស់យើងគឺបានកើតពីអំនាចនៃព្រះវិញ្ញាបរិសុទ្ធ។ រួចយើងត្រូវស្វែងរកព្រះដែលមានព្រះជន្មគង់ដោយការទំនាក់ទំនង។ដូច្នេះយើងត្រូសម្អាតការស្មោះត្រង់នៃវិញ្ញាណរួចឆ្លើយតបនៅការសុគតរបស់ព្រះយេស៊ូវ ទៅចំពោះចិត្តដែលពេញដោយអំពើបាបដោយផ្ទល់។

ដូច្នេះអស់អ្នកណាដែលបានជ្រមុជទឹកគួរតែរីករាយក្នុងសេចក្តីប្រកបជាមួយព្រះដែលមានព្រះជន្មគង់នៅ។នេះហើយជាសេចក្តរីករាយនៅក្នុងជីវិតជាគ្រីស្ទបរិស័ទ។ហើងគួរតែមានបទពិសោធន៍ពីរព្រឹត្តការណ៍នៅក្នុងចិត្តរបស់យើង គឺសេចក្តីស្លាប់និងការរស់ឡើងវិញ នៅក្នុងជីវិតយើង។នេះគឺជាអត្ថន័យពិតនៃការជ្រមុជទឹក។ ព្រះយេស៊ូវគ្រីស្ទបានសង្កត់ថា ប្រសិនបើគ្មានរណាបដិសេដ្ឋខ្លួនឯងនោះទេនោះគាត់នឹងពិតថាមិនអាចដើរតាមព្រះយេស៊ូវគ្រីស្ទបានឡើយ។

**សេចក្ដីបញ្ចប់**

ពួកបរិសុទ្ធរបស់ខ្ញុំអើយយើងត្រូវតែចេញទៅគ្រប់ជាតិសាសន៍ដើម្បីផ្សាយដំណឹងល្អទៅពួកគេ ហើយនិង សង់ក្រុមជំនុំរបស់ព្រះគ្រីស្ទដោយដឹងពីអត្ថន័យនៃពិធីជ្រមុជទឹកនៅក្នុងជីវិតរស់នៅរបស់យើង។ យើងរាល់គ្នាបានសង្គ្រោះចេញពីអំពើបាប រួចទទួលនៅឈើឆ្កាងរបស់ទ្រង់ និងការរស់ឡើងវិញជារបស់ខ្ញុំ។ដូច្នេះយើងមាននៅសញ្ញាដែលមិនចេះប្រែប្រួលនៅក្នុងយើងដោយការជ្រមុជនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ ជាមួយនឹងការជ្រមុជទឹកដោយទឹកក្នុងជីវិតរស់នៅក្នុងក្រុមជំនុំ។ដូច្នេះយើងត្រូវរីករាយដើរតាមជាមួយព្រះដែលមានព្រះជន្មគង់នៅ ដោយចេញពីបញ្ញាចិត្តជ្រះថ្លា។ បន្ទាប់មកទៀតយើងអាចថ្វាយសិរីល្អនិងរីករាយជាមួយនឹងព្រះនៅក្នុងជីវិតរស់នៅរបស់យើង។ *តើអ្នកមានបញ្ញាចិត្តជ្រះថ្លារឺទេ?តើអ្នករីករាយការប្រកបរឺទេ? ហើយតើអ្នកបដិសេដខ្លួនឯងរឺទេ?*

| **មេរៀនទី 3 ចូរទៅគ្រប់ទាំងសាសន៍ (Go to all nations)** |
|---|

ព្រះគម្ពីរម៉ាថាយ ជំពូក២៨:១៩-២០)

*១៩ ដូច្នេះចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សគ្រប់ទាំងសាសន៍ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធចុះ ២០ ហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្តីដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាផង ដរាបដល់បំផុតកល្ប។ អាម៉ែន!*

សេចក្តីផ្តើម

នៅក្នុងមនុស្សសម័យនេះគឺមានបញ្ហាជាច្រើនមានដូចជា បញ្ហានយោបាយ បញ្ហាហិរញ្ញវត្ថុ បញ្ហាវប្បធម៌ និង បញ្ហាសង្គមជាដើម។ យើងបានវង្វេងមុនបញ្ហាទាំងនេះនៅក្នុងថ្ងៃបណ្តោះអាសន្ន ដោយយើងស្វែងរកនៅវិធីជាច្រើនដើម្បីដោះស្រាយ។បន្ទាប់យើងបានដោះស្រាយវាបានដោយការស្តាឡើងវិញនសកម្មភាពផ្សាយដំណឹងល្អនេះជាព័ន្ធកិច្ចចំបងបំផុតនៅក្នុងបេសកម្មក្រុមជំនុំ។យើងជឿទៅលើដំណឹងល្អ។នៅក្នុងប្រទេសកូរ៉េខាងត្បូង សហរដ្ឋអាមេរិកនិងកម្ពុជាដំណោះស្រាយយ៉ាងពិតប្រាកដនោះគឺ ការត្រឡប់ទៅរកការបង្គាប់ដ៏អស្ចារ្យ ដែលមានក្នុងព្រះគម្ពីរ ម៉ាថាយ ជំពូក២៨:១៩-២០ ហើយស្តាប់បង្គាប់ដោយផ្ទាល់ដូចជាព័ន្ធកិច្ចចំបងនៃក្រុមជំនុំ។នៅក្នុងពេលនេះយើងគិតថាហេតុអ្វីបានជាព័ន្ធកិច្ចមានសារៈសំខាន់ម្លេះ និងហេតុអ្វីបានជាព័ន្ធកិច្ចជាប្រភពចំបងនៃបញ្ហា?

នៅពេលដែលខ្ញុំបានទទួលនៅព័ន្ធកិច្ចក្នុងប្រទេសកម្ពុជា ខ្ញុំបានជួបបញ្ហានៃពិធីបុណ្យជ្រមុជទឹកដែលថាគេបានដាក់អ្នកជឿឲ្យជ្រមុជទឹកឲ្យអ្នកជឿដំបូង។នៅក្នុងព្រះគម្ពីរ ម៉ាថាយ ជំពូក២៨:១៩-២០ បានបង្ហាញពីសេចក្តីបង្គាប់បួនគឺ ចូរទៅគ្រប់ជាតិសាសន៍ បញ្ចុះបញ្ចូលពួកគេ ដើម្បីបង្រៀនព្រះបន្ទូល

ព្រះ និងឲ្យគេស្តាប់បង្គាប់គ្រប់ទាំងព្រះបន្ទូលនៅក្នុងជីវិតរបស់គាត់។ នៅក្នុងព្រះគម្ពីរ ម៉ាកុស ជំពូក១៦ បានសំដែងសេចក្តីបង្គាប់ថា ចូរដើរទៅឯផែនដីនេះចុះរួចហើយប្រកាស់ដំណឹងល្អដល់ពួកគេចុះ។ នៅក្នុងនេះមានឃ្លាកិរិយាស័ព្ទពីរ គឺ ដើរទៅ ហើយនិងប្រកាស់ ហើយវាបានសង្ខេបថានៅព្រឹត្តការណ៍នេះថា *ចូរដើរទៅគ្រប់ទាំងជាតិសាសន៍ ប្រកាស់ដំណឹងល្អ ហើយនិង ផ្សាយដំណឹងល្អទៅពួកគេ។*

គឺដូចជាយើងបានភ្ជាប់ខពីរជាមួយគ្នានោះយើងបានឃើញនៅសេចក្តីបង្គាប់ដ៏អស្ចារ្យនៃព្រះជាម្ចាស់ គឺត្រូវតែផ្សាយដំណឹងល្អ។ យើងដឹងថាការបង្កើតសិស្សគឺជាព័ន្ធកិច្ចចំបងរបស់ក្រុមជំនុំ។ តើយើងគួរធ្វើអ្វី?វាជាការផ្សាយដំណឹងល្អ។ អ្នកគួរតែទៅគ្រប់ទាំងជាតិសាសន៍ ហើយដើរឲ្យពេសពេញលោកិយ៍ដើម្បីផ្សាយដំណឹងល្អ។ ធ្វើពាក្យនេះឲ្យខ្លីទៅព័ន្ធកិច្ចចំបងគឺ ផ្សាយដំណឹងល្អទៅគ្រប់ជាតិសាសន៍។*តើការផ្សាយដំណឹងល្អជាអ្វី?*

**ទីមួយៈ ការផ្សាយដំណឹងល្អគឺជាមូលដ្ឋានគ្រឹះរបស់ក្រុមជំនុំ**

ក្រុមជំនុំដែលព្រះជាម្ចាស់បានមានបន្ទូលថានឹងសង់ក្រុមជំនុំទ្រង់ឡើងគួរតែបានចាប់ផ្តើមជាមួយការផ្សាយដំណឹងល្អ។ សកម្មភាពចំបងដែលពួកសាវ័កបានទទួលនោះគឺ ការផ្សាយដំណឹងល្អនេះឯង។ យើងគួរតែប្រកាស់ដំណឹងល្អដើម្បីសង់ក្រុមនុំរបស់ព្រះជាម្ចាស់។ គឺដូចជាយើងប្រកាស់ព្រះបន្ទូលរបស់ព្រះ ហើយមានអ្នកស្តាប់ និងប្រែចិត្ត និងទទួលជឿតាមរយៈការធ្វើការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ នេះហើយគឺជាសេចក្តីបង្គាប់នៃភាពជាសិស្សរបស់ព្រះទៅកាន់ក្រុមជំនុំរបស់ព្រះអង្គ។ វាជាក្រុមជំនុំដែលមិនមែនជាភាពនៃសាវ័កដែលគ្មានភាពជាសាវ័ក ហើយបាត់បង់អំនាច ចេស្តា និងវត្តមាននៃភាពជាសាវ័ក។ *តើអ្វីទៅដែលជាសញ្ញានៃភាពជាសាវ័កនៃក្រុមជំនុំដំបូង?* វាគឺជាការផ្សាយដំណឹងល្អទៅកាន់លោកិយ៍។ ហើយជាចុងក្រោយគឺទាមទាឲ្យក្រុមជំនុំផ្សាយដំណឹងល្អ។

មូលដ្ឋាននៃគ្រីស្ទបរិស័ទគឺបានគ្រាស់ហៅពេញដោយអំនាចចេស្តាមួយ គឺខ្ញុំជាព្រះគ្រីស្ទ។ ប៉ុន្តែពួកគេបានព្រងើយកន្តើយចំពោះតម្លៃនេះហើយពួកគេបាសក្លាយជាពុករលួយបាត់បង់ភាពជាអ្នកតំណាងនៃព្រះគ្រីស្ទ។ព្រឹត្តការណ៍ដែលថាព្រះគ្រីស្ទនឹងគង់ជាមួយពួកគេនឹងកើតមានឡើងនៅក្នុងបទពិសោធន៍នៃអ្នផ្សាយដំណឹងល្អនោះ។ពីព្រោះបទពិសោធន៍ដ៏អស្ចារ្យថានឹងកើតមានឡើងជាមួយអ្នកផ្សាយដំណឹងល្អនិងបេសកជននោះគឺ អេម៉ាញូអែល ដែលពួកគេបានដើរនៅក្នុងផ្លូវនៃព្រះពរ។

ទោះបីជាយ៉ាងណាការផ្សាយដំណឹងល្អខ្លួនឯងនឹងបង្ហាញនៅរូបឆ្លុះនៃសេចក្តីសុចរិតសេចក្តីមេត្តាករុណានិង សេចក្តីស្មោះត្រង់ក្នុការសង្កេតមើលនៅព្រឹត្តការណ៍នៅក្នុងលោកិយ៍នេះ ដែលនេះជាកូនសោរសម្រាប់បើកទ្វារនៃនគរស្ថានសួគ៌។នៅក្នុងឆ្នាំថ្មីនេះយើងគួរតែប្រើកូនសោរនេះក្នុងជីវិតរស់នៅរបស់យើង។

**ទីពីរ៖ គ្រប់ជាតិសាសន៍គឺជាកម្មវត្ថុសម្រាប់ការផ្សាយដំណឹងល្អ**

ពាក្យថា *ជាតិសាសន៍* គឺបានលេចឡើងដំបូងបន្ទាប់ពីព្រឹត្តិការណ៍នៃប៉មបាបិល។ ព្រះគម្ពីរលោកុប្បត្តិជំពូក១១:៨ នេះជាការកំណត់ ក្រុមគ្រួសារ សង្គម ជាតិសាសន៍ ប្រទេសជាតិ ។ល។ បានប្រើរហូតមកដល់សព្វថ្ងៃនេះ។ ឥឡូវនេះគឺមានប្រទេសចំនួន២៦០នៅលើពិភពលោក។ ព្រះជាម្ចាស់បានបង្គាប់យើងឲ្យទៅគ្រប់ជាតិសាសន៍។នៅត្រង់ចំនុចនេះយើងអាចស្វែងយល់ថាព្រះជាម្ចាស់ពិតជាយកចិត្តទុកដាក់ចំពោះការផ្សាយដំណឹងល្អទៅគ្រប់ទាំងគ្រួសារណាស់។ហើយយើងក៏គួរតែចេញទៅបួនពាន(៤០០០)ភូមិនិងម្ភៃប្រាំខេត្តក្រុងនៅក្នុងប្រទេសកម្ពុជាជាមួយនឹងដំណឹងល្អ ដោយយោងទៅតាមសេចក្តីបង្គាប់របស់ព្រះយេស៊ូវគ្រីស្ទ។

ព្រះជាម្ចាស់មានបំណងផ្សាយដំណឹងល្អគ្រប់ជាតិសាសន៍ដោយបានចាប់ផ្តើមដោយការរួបរួមតែមួយនៃគ្រួសារ រួចហើយពង្រីកទៅគ្រប់ជាតិសាសន៍ រឺគ្រប់កុលសម្ព័ន។ ដូចជាកុលសម្ព័ននៃភ្នំមួយ បានទទួលដំណឹងល្អជំនឿនោះនឹងផ្សាយចេញទៅមនុស្សនិងសាសន៍ដទៃទៀតនៃភាគខាងកើតឈៀងខាងត្បូងនៃភូមិភាគអាស៊ី ដោយអំនាចនៃព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះយើងត្រូវដឹងថាការផ្សាយដំណឹងល្អមួយគ្រួសារគឺមានសារៈសំខាន់ណាស់។

**ទីបី៖ ការផ្សាយដំណឹងល្អគឺជាសកម្មភាពនៃការលះបង់**

ពេលរបស់យើង រូបកាយរបស់យើង សម្ភារៈរបស់យើង ការផ្គត់ផ្គង់របស់យើង។ល។ មានការស្នើរសុំឲ្យមានការលះបង់ខ្ពស់ជាសញ្ញានៃស្វាមីភ័ក្ត។ ការសិក្សានៃបេសកម្មឲ្យន័យការផ្សាយដំណឹងល្អថា គ្រីស្ទបរិស័ទប្រកាស់ដំណឹងល្អទៅវប្បធម៌ដទៃទៀត។ព្រះគម្ពីរម៉ាកុសបាននាយាយអំពីការប្រកាស់ដំណឹងល្អនៅក្នុងគ្រប់នៃការបង្កើតយ៉ាងលំអិត ព្រះគម្ពីរម៉ាកុសជំពូក១៦:១៥។ យើងគួរតែចាប់ផ្តើមការជ្រមុជទឹក ការបង្រៀន ហើយឲ្យគេកាន់តាមសេចក្តីបង្គាប់ររបស់ព្រះជាម្ចាស់នៅក្នុងជីវិត ហើយបន្ទាប់មក ពួកគេគួរតែក្រោយជាអ្នកផ្សាយដំណឹងល្អ។ពួកគេគួរតែទៅគ្រប់ទាំងជាតិសាសន៍ដើម្បីប្រកាស់ដំណឹងល្អទៅអ្នកដែលមិនទាន់បានជឿព្រះយេស៊ូវគ្រីស្ទឲ្យគេបានជឿដែរ។នេះជាបេសកម្មដ៏ងស្វារ្យរបស់ព្រះជាម្ចាស់។យើងគួរតែធ្វើឲ្យប្រាកដនិង ត្រូវតែបម្រើទៅកាន់ក្រុមជំនុំ។

សេចក្តីបង្គាប់ដែលធំជាងគេរបស់ព្រះជាម្ចាស់គឺការផ្សាយដំណឹងល្អដែលយើងត្រូវតែទៅគ្រប់ទាំងកុលសម្ព័នដើម្បើផ្សាយដំណឹងល្អគ្រប់មនុស្ស។ដូច្នេះយើងត្រូវតែពិនិត្យមើលសកម្មភាពរបស់យើងដែរថាយើងគួរតែបម្រើដំណឹងល្អនិងបេសកម្ម។